# វត្តសាមគ្គីធម្មិការាម

**WATT SAMAKKI DHAMMIKARAM**
**26 Rugby Road Brooklyn, NY 11226**
**www.wattsamakki.org Tel: 718 856-8918**


**EP/WSD**
**19 APRIL 2025**



# បុណ្យចូលឆ្នាំខ្មែរ



## ចូលឆ្នាំថ្មីប្រពៃណីខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

អាត្មាភាពជាព្រះសង្ឃ និងជាអគ្គនាយក ប្រធាន លោកអាចារ្យ គណៈកម្មការ ពុទ្ធបរិស័ទក្នុង **វត្តសាមគ្គីធម្មិការាម** ក្នុងឱកាសឆ្នាំថ្មី សូមប្រសិទ្ធិពរជ័យ សិរីសួស្តី សុភមង្គល ដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ឱ្យជួបតែពុទ្ធពរទាំង ៤ ប្រការគឺ  អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ឆ្នាំថ្មី ចូលមកដល់នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៥ វេលាម៉ោង ៤ និង ៤៨ នាទីព្រឹក អាស្រ័យដូចជំរាបជូនខាងលើនេះ អាត្មាភាព យើងខ្ញុំទាំងអស់គ្នា ជាគណៈកម្មការ វត្តសាមគ្គីធម្មិការាម សូមគោរពអញ្ជើញ ញោមញាតិ បងប្អូន ប្រុសស្រី ពុទ្ធបរិស័ទជិតឆ្ងាយ គ្រប់មជ្ឈដ្ឋាន មេត្តាចូលរួមពិធីបុណ្យចូលឆ្នាំថ្មីនេះ ឱ្យបានច្រើនកុះករ ដើម្បីសន្សំ បុណ្យ ទាន សីល ភាវនា  គ្រប់ៗរូប និងបង្សុកូល ឧទ្ទិសកុសល ជូនមាតាបិតា ញាតិការទាំង ៧ សន្តាន ដែលបានស្លាប់ទៅកាន់បរលោក ។

## កម្មវិធីចូលឆ្នាំខ្មែរ

**ថ្ងៃសៅរ៍ ៧ រោច ខែ ចេត្រ ឆ្នាំ ម្សាញ់ សប្តស័ក ព.ស. ២៥៦៨  ត្រូវនឹងថ្ងៃទី១៩ ខែ មេសា ឆ្នាំ ២០២៥**

**ម៉ោង ០៩:00** នាទីព្រឹក ជួបជុំពុទ្ធបរិស័ទជិតឆ្ងាយ នមស្ការ សមាទានសីល ចម្រើនព្រះបរិត្ត សម្តែងធម៌ទេសនារាប់បាត្រ វេរចង្ហាន់ប្រគេនព្រះសង្ឃ និង ឧទ្ទិសបុណ្យដល់ញាតិ។

**លុះម៉ោង ០១:00** នាទីថ្ងៃត្រង់ ជួបជុំគ្នា ដង្ហែក្បួនតាមផ្លូវមុខវត្ត ស្រង់ទឹកព្រះ មានសម្តែងរបាំជូនពរ និង របាំត្រុដិ ព្រមទាំងរាំច្រៀងកម្សាន្តចិត្តតាមប្រពៃណីជាតិខ្មែរទៀតផង ។

**ថ្ងៃអាទិត្យ ៨រោច ខែ ចេត្រ ឆ្នាំ ម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែ មេសា ឆ្នាំ ២០២៥**

**ម៉ោង ០៩:00** នាទីព្រឹក ជួបជុំពុទ្ធបរិស័ទជិតឆ្ងាយ នមស្ការ សមាទានសីល ចម្រើនព្រះបរិត្ត និង បង្សុកូល រាប់បាត្រ វេរចង្ហាន់ប្រគេនព្រះសង្ឃ ដារឆ្លងបញ្ចប់កម្មវិធីបុណ្យ ៕

**បញ្ជាក់ថា៖** ជាធម្មតាចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ចាប់ផ្តើមតាំងពីថ្ងៃទី១៤ ១៥ ១៦ ខែ មេសា ឆ្នាំ ២០២៥ ប៉ុន្តែពុទ្ធបរិស័ទយើងជាប់រវល់ ទើបលើកទៅថ្ងៃ សៅរ៍ អាទិត្យ វិញ។

*សូមអរព្រះគុណ និង អរគុណ !*

# HAPPY CAMBODIAN NEW YEAR

Watt Samakki is pleased to inform you that Cambodian New Year will start on April 14th-16th, 2025. In addition, we will celebrate the last day of our New Year on Saturday-Sunday April 19th-20th, 2025. We would like to invite everyone to come and join to celebrate the year of the Tiger. The events are as followed:

## Saturday (April 19, 2025)

**9:00 am:** Gathering at the temple, paying respect to the Triple Gems, Observing the Five precepts, Dharma talk, and offering Alms. Buddhist monks will have lunch and dedicate merits to the departed family members that are no longer with us in our world. We will perform the Robam Chunpor, Robam Trud, and dance to the music etc...

**1:00 pm:** Cambodian New Year parade on the street, starting in front of the temple (Rugby Rd. between Caton Ave and Church Ave), bathe Buddha statue with holy water, Robam Chunpor, Robam Trud, and dance to the music etc...

## Sunday (April 20, 2025)

**9:00 am:** Gathering at the temple, paying respect to the Triple Gems, Observing the Five precepts, Dharma talk, and offering Alms. Buddhist monks will have lunch and dedicate merits to the departed family members that are no longer with us in our world.

On this occasion of Cambodian New Year, we would like to bless everyone with longevity, beauty, happiness, and strength forever.

**Sincerely Yours,**

| Abbot | Chairman | President |
|---|---|---|
| **Ven. Rithy Sun** | **Kenny Seng** | **Parima In** |